ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតជូនពរ

## សូមគោរពជូន
## សម្តេចធម្មវិសុទ្ធវង្សា សៅ ទី ហេង សំរិន

**សម្តេចធម្មវិសុទ្ធវង្សា ជាទីគោរពដ៏ខ្ពង់ខ្ពស់**

ក្នុងឱកាសដ៏បវរសួស្តី សិរីមង្គលមហាប្រសើរ នៃពិធីបុណ្យចម្រើនជន្មាយុគម្រប់៨៣ឆ្នាំ ឈានចូល៨៤ឆ្នាំ របស់ **សម្តេចធម្មវិសុទ្ធវង្សា** នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១នេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមសម្តែងនូវអំណរសាទរយ៉ាងជ្រាលជ្រៅ ជូនចំពោះ **សម្តេចធម្មវិសុទ្ធវង្សា** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កាយពលមាំមួន បញ្ញាញាណភ្លឺថ្លា និងមានជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសដ៏មហាប្រពៃនេះ យើងខ្ញុំសូមអនុញ្ញាតសម្តែងនូវការកោតសរសើរដ៏ស្មោះ ចំពោះទឹកចិត្តដ៏ថ្លៃថ្លា និងសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចធម្មវិសុទ្ធវង្សា** ដែលជានិច្ចជាកាលតែងតែរួមដំណើរជម្រុញលើកទឹកចិត្ត និងគាំទ្រ **សម្តេចអគ្គមហាពញាចក្រី** ក្នុងបេសកកម្មដឹកនាំស្ថាប័ននីតិប្បញ្ញត្តិដើម្បីឲ្យប្រទេសជាតិមានសន្តិភាព និងស្ថិរភាព ក៏ដូចជារួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិមនុស្ស នៅព្រះរាជាណាចក្រកម្ពុជា។ **សម្តេច** ជាឧត្តមភរិយា ជាមាតា ជាជីដូន ជាជីដូនទួត ប្រកបដោយព្រហ្មវិហារធម៌ គុណធម៌ និងជាគំរូដ៏ប្រពៃសម្រាប់ស្ត្រីគ្រប់រូប។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់ទេវតា និងវត្ថុស័ក្តិសិទ្ធិលើលោក ប្រសិទ្ធពរជ័យជូនចំពោះ **សម្តេចធម្មវិសុទ្ធវង្សា សៅ ទី ហេង សំរិន និង សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី** ទទួលបានពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចធម្មវិសុទ្ធវង្សា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃ អង្គារ ១៣កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០២១

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**

**រដ្ឋមន្ត្រី**

ព្រុំ សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh